ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩....ណ.ល.ទ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និង ទិវាកុមារកម្ពុជា ឆ្នាំ២០១៧

*- សូមថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*- បងប្អូនជនរួមជាតិ និងក្មួយៗកុមារា កុមារីជាទីស្រឡាញ់ !*

ក្នុងឱកាសដ៏មហោឡារិកនៃ ***ខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧*** នេះ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមសម្តែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំទិវាកុមារអន្តរជាតិនេះ និងសូមថ្លែងនូវសារលិខិតថ្វាយ និងប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនជនរួមជាតិ ជាពិសេសក្មួយៗកុមារជាទីស្រឡាញ់ អំពីឆន្ទៈនិងបុព្វហេតុក្នុងការបន្តលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ និងសូមលើកទឹកចិត្តឱ្យបងប្អូនជនរួមជាតិយើងទាំងអស់រួមគ្នាបន្តពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរ ដើម្បីឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជា។

ឆ្នាំនេះ ទិវាកុមារកម្ពុជា និងទិវាកុមារអន្តរជាតិ ១ មិថុនា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ "***លើកកម្ពស់ការចូលរួមរបស់កុមារ ដើម្បីអភិវឌ្ឍន៍សង្គម***" និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ក្រោមប្រធានបទ "***សូមការពារកុមារពីពលកម្មកុមារ នៅក្នុងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ***" ដើម្បីលើកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយរបស់កុមារ ជាពិសេស ជំរុញកុមារឱ្យបានចូលរួមគ្រប់សកម្មភាព ដែលមានផលប្រយោជន៍ដល់សង្គម និងការពារកុមារពីពលកម្មកុមារគ្រប់ទម្រង់។

ព្រះរាជាណាចក្រកម្ពុជាកំពុងរក្សាបាននូវស្ថិរភាពនយោបាយ សុខសន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈយ៉ាងល្អប្រសើរទូទាំងប្រទេស ដែលកត្តាសារវន្តទាំងនេះ បានបង្កលក្ខណៈអំណោយផលដល់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមជាតិ ក្នុងគោលដៅកសាងអនាគតកម្ពុជាមួយដ៏រុងរឿង ឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជន។ ជាមួយនឹងប្រធានបទ ដែលបានលើកឡើងខាងលើ ទិវាដ៏មានសារសំខាន់នេះ បានជំរុញឱ្យយើងត្រូវខិតខំឱ្យបានខ្លាំងក្លាថែមទៀត លើការអនុវត្តសិទ្ធិចម្បងទាំងបួនរបស់កុមារឱ្យមានប្រសិទ្ធភាព ក្នុងនោះត្រូវយកចិត្តទុកដាក់លើសិទ្ធិចូលរួមរបស់កុមារ ដោយផ្តល់ឱកាសឱ្យកុមារបានជួបជុំដោយសន្តិវិធី សម្តែងមតិយោបល់

ទទួលបានព័ត៌មាន និងចូលរួមធ្វើការសម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង លើបញ្ហាដែលពាក់ព័ន្ធនឹងកុមារ ដោយឈរលើគោលការណ៍គ្មានការរើសអើង និងឧត្តមប្រយោជន៍របស់កុមារ។

នៅលើពិភពលោកយើងសព្វថ្ងៃនេះ មានប្រជាជនជាង ១,៥៣ពាន់លាននាក់ កំពុងរស់នៅក្នុងប្រទេសដែលរងផលប៉ះពាល់ដោយសារស្ថានភាពជម្លោះ អំពើហិង្សា និងភាពងាយបែកបាក់។ ទន្ទឹមនឹងនេះ មានប្រជាជនប្រមាណ២០០លាននាក់ ទទួលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយជារៀងរាល់ឆ្នាំ ហើយដែល១ភាគ៣នៃប្រជាជនទាំងនោះ គឺជាកុមារ។ ក្នុងចំណោមកុមារ១៦៨លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់ដែលទទួលរងផលប៉ះពាល់ដោយសារស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ ភាគច្រើនជាប់ពាក់ព័ន្ធក្នុងពលកម្មកុមារ។ ទិវាពិភពលោកប្រឆាំងពលកម្មកុមារឆ្នាំនេះ ផ្តោតលើផលប៉ះពាល់ដោយសារស្ថានភាពជម្លោះ និងគ្រោះមហន្តរាយមកលើពលកម្មកុមារ។

ស្ថានភាពជម្លោះ និងគ្រោះមហន្តរាយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់អាយុជីវិតរបស់ប្រជាជន។ ស្ថានភាពជម្លោះ និងគ្រោះមហន្តរាយបានសម្លាប់ ធ្វើឱ្យពិការ ធ្វើឱ្យមានរបួសស្នាម បង្ខំឱ្យប្រជាជនចាកចេញពីផ្ទះសម្បែង បំផ្លិចបំផ្លាញ មុខរបរចិញ្ចឹមជីវិត ព្រៀប្រានប្រជាជនឱ្យធ្លាក់ចូលក្នុងភាពក្រីក្រនិងទុរភិក្ស និងធ្វើឱ្យប្រជាជនស្ថិតនៅក្នុងស្ថានភាព ដែលសិទ្ធិជាមូលដ្ឋានរបស់មនុស្សត្រូវបានរំលោភបំពាន។ ជារឿយៗ នៅពេលដែលសាលារៀនត្រូវបានបំផ្លិចបំផ្លាញ និងសេវាជាមូលដ្ឋានត្រូវបានកាត់ផ្តាច់ កុមារគឺជាអ្នកដែលទទួលរងគ្រោះមុនដំបូងគេបង្អស់។ កុមារជាច្រើនត្រូវបានជម្លៀសចេញពីប្រទេស ឬក្លាយជាជនភៀសខ្លួននៅក្នុងប្រទេសដទៃជាពិសេស ពួកគេ គឺជាជនរងគ្រោះដោយសារអំពើជួញដូរ និងពលកម្មកុមារ។ ទីបំផុត កុមាររាប់លាននាក់ ត្រូវបានព្រៀឱ្យធ្លាក់ចូលទៅក្នុងពលកម្មកុមារដោយសារស្ថានភាពជម្លោះ និងគ្រោះមហន្តរាយនានា។ ខណៈដែលពិភពលោកកំពុងខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវការលុបបំបាត់ពលកម្មកុមារ នៅឆ្នាំ២០២៥ ក្នុងថ្ងៃទិវាពិភពលោកប្រឆាំងពលកម្មកុមារនេះ "សូមរួមគ្នាជំរុញឱ្យមានការបញ្ចប់ពលកម្មកុមារ នៅក្នុងតំបន់ទាំងឡាយដែលរងគ្រោះដោយសារស្ថានភាពជម្លោះ និងគ្រោះមហន្តរាយផ្សេងៗ"។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមន្ត្រីរាជការទាំងអស់នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏ដូចជាថ្នាក់ដឹកនាំនិងមន្ត្រីនៃស្ថាប័នព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា ក្រសួង-ស្ថាប័ននានា អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន មាតាបិតាអ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងអ្នកថែទាំកុមារទាំងអស់ ដែលបានចំណាយទាំងកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងថវិកាប្រកបដោយការទទួលខុសត្រូវខ្ពស់ រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចូលរួមចំណែកយ៉ាងសកម្មលើវិស័យកុមារ ដែលជាវិស័យអាទិភាពសំដៅធ្វើឱ្យសម្រេចបាននូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម ក្នុងបុព្វហេតុបង្កើតធនធានមនុស្សប្រកបដោយចំណេះដឹង ជំនាញវិជ្ជាជីវៈ ព្រមទាំងសមត្ថភាពខ្ពស់ក្នុងការប្រកបមុខរបរ ការងារ កសាងជីវភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានឆន្ទៈមោះមុត ចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសនាពេលអនាគត។

កុមារត្រូវការចាំបាច់នូវការអភិវឌ្ឍផ្នែករាងកាយ បញ្ញា ស្មារតី និងការសិក្សារៀនសូត្រ ហេតុនេះកុមារត្រូវការការថែទាំ ការជួយទំនុកបម្រុងពីគ្រួសារ និងសង្គម ជាពិសេសលើកកម្ពស់ការចូលរួមរបស់កុមារ ដែលជាការរៀនសូត្រ ដើម្បីអភិវឌ្ឍខ្លួន និងត្រៀមខ្លួនក្លាយជាមនុស្សពេញវ័យប្រកបដោយសមត្ថភាព និងជាពលរដ្ឋដ៏សកម្ម។ កុមារមានការយល់ដឹងពីជីវិត មានគំនិត អារម្មណ៍ និងទស្សនៈផ្ទាល់ខ្លួន អាចកសាងទំនុកចិត្ត គោរពខ្លួនឯង និងមានភាពជាអ្នកដឹកនាំ។ ការងារនេះ អាចអនុវត្តបានជោគជ័យ អាស្រ័យដោយមានគោលនយោបាយ និងមានការវិនិយោគដ៏សមស្របសម្រាប់កុមារនិងគ្រួសារ ដើម្បីកសាងធនធានមនុស្សប្រកបដោយសក្តានុពលសម្រាប់អភិវឌ្ឍប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតុបករណ៍អន្តរជាតិជាច្រើន ដូចជា អនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារបន្ថែមស្តីពីការជួញដូរ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ អនុសញ្ញាស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច អនុសញ្ញាស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ចូលធ្វើការ អនុសញ្ញាស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការសុំកូនអន្តរប្រទេស។ល។ ជាមួយគ្នានេះដែរ ដើម្បីបន្តលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ រាជរដ្ឋាភិបាលបានបង្កើតច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ជាច្រើនដូចជា៖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការងារ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច គោលនយោបាយថែទាំជំនួសចំពោះកុមារ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍន៍កុមារ ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ ព្រមទាំងច្បាប់ និងផែនការជាច្រើនផ្សេងទៀត។

បច្ចុប្បន្ន កម្ពុជាបានធ្វើឱ្យស្ថានភាពសិទ្ធិកុមារ កាន់តែមានភាពល្អប្រសើរជាលំដាប់ ដូចជាអត្រាមរណភាពរបស់កុមារបានថយចុះជាលំដាប់ ការចុះឈ្មោះចូលរៀនមានការកើនឡើង ការជួយសង្គ្រោះកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឱ្យកុមារទទួលបានការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើសមាហរណកម្មទៅក្នុងសង្គម និងការលើកកម្ពស់ការងារសមរម្យនិងសុវត្ថិភាពកុមារ។ កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល គឺធានាឱ្យកុមារគ្រប់រូប ទទួលបាននូវការគាំទ្រសម្រាប់ការចាប់ផ្តើមជីវិតដ៏ល្អ ក្នុងការរស់រាន និងអភិវឌ្ឍន៍ពោរពេញទៅដោយសក្តានុពល ហើយក្លាយជាពលរដ្ឋកម្ពុជា ដែលមានការទទួលខុសត្រូវក្នុងសង្គម ដែលជាតម្រូវការចាំបាច់សម្រាប់ប្រទេសកម្ពុជា ក្នុងការសម្រេចគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ម្យ៉ាងវិញទៀត ដើម្បីឱ្យការអនុវត្តការងារកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារដែលដឹកនាំដោយកុមារជាច្រើន ត្រូវបានបង្កើត មានដូចជា ចលនាយុវជនកាកបាទក្រហមកម្ពុជា និងកាយរឹទ្ធិកម្ពុជា ក្លឹបកុមារនៅតាមសាលារៀន បណ្តាញកុមារអ្នកតស៊ូមតិ ចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ ដែលពួកគេក្លាយជាចលនាយុវជន ឬកុមារឈានមុខក្នុងការកសាង និងអភិវឌ្ឍន៍សង្គម។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលក៏បានផ្តល់នូវឱកាសដល់កុមារក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ក្នុងការចូលរួមក្នុងវេទិកានៅគ្រប់កម្រិត ទាំងថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ រាល់មតិយោបល់របស់កុមារត្រូវបានយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍន៍សិទ្ធិកុមារ។ ការជំរុញឱ្យកុមារបានចូលរួមក្នុងសកម្មភាពនានា មានន័យថាការដោះស្រាយបញ្ហារបស់ពួកគេ កាន់តែមានប្រសិទ្ធភាពខ្ពស់ ព្រោះមានតែកុមារទេ ដែលដឹងពីស្ថានភាព តម្រូវការ និងបញ្ហារបស់គេច្បាស់លាស់។

ទោះបីជាកិច្ចខិតខំប្រឹងប្រែងទទួលបានជោគជ័យយ៉ាងច្រើនក៏ដោយ កម្ពុជានៅតែបន្តទទួលរងនូវឥទ្ធិពលពីការប្រើប្រាស់គ្រឿងញៀន ការជួញដូរ ការរំលោភបំពានផ្សេងៗ ការប៉ះពាល់ពីអំពើហិង្សា និងការចូលរួមរបស់កុមារនៅមានកម្រិតនៅឡើយ។ ស្ថានភាពនេះបានបង្កឱ្យកុមារទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយមិនបានទទួលការអប់រំរៀនសូត្រ ការថយចុះទំនាក់ទំនងក្នុងសង្គម និងខ្វះការទទួលបានព័ត៌មានផ្សេងៗ។

ក្នុងស្មារតីនេះ ដើម្បីបន្តចូលរួមការពារ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងឱកាសនៃទិវាកុមារអន្តរជាតិ ១ មិថុនា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមអំពាវនាវ ដូចតទៅ៖

១.បង្កើនការយល់ដឹងដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋក្នុងសហគមន៍ ក្នុងការកំណត់អត្តសញ្ញាណពលកម្មកុមារ និងលើកកម្ពស់ការយល់ដឹងចំពោះផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយ និងលើកកម្ពស់ភាពក្លាហានរបស់កុមារ និងគ្រួសារក្នុងការរាយការណ៍អំពីការរំលោភបំពានផ្សេងៗ។

២.ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តកិច្ចសហការអនុវត្តសិទ្ធិចម្បងជាមូលដ្ឋានរបស់កុមារ សំដៅបម្រើផលប្រយោជន៍ដល់កុមារគ្រប់ៗរូប។

៣.ក្រុមប្រឹក្សារាជធានី ខេត្ត ឃុំ សង្កាត់ ត្រូវបង្កលក្ខណៈឱ្យមានតំណាងកុមារចូលរួមរាល់កិច្ចប្រជុំពិភាក្សាពាក់ព័ន្ធនឹងសកម្មភាពនានា គម្រោងទាំងឡាយណា ដែលមានប្រយោជន៍ចំពោះកុមារ និងសូមផ្លាស់ប្តូរគំហើញរបទ ដែលថាកុមារមានគំនិតក្មេងខ្ចី ក្នុងការចូលរួមបញ្ចេញនូវបតិយោបល់។

៤.ក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន គ្រួសារ មាតាបិតា អ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងអ្នកថែទាំកុមារទាំងអស់ សូមបង្កលក្ខណៈឱ្យកុមារបានចូលរួម ក្នុងសកម្មភាពសង្គមនានាប្រកបដោយគុណភាព និងប្រសិទ្ធភាព ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ស្របតាមការវិវឌ្ឍន៍ស្ថានភាពកុមារនៅកម្ពុជា។

៥. ពង្រឹងសកម្មភាពចុះផ្តល់សេវានៅតាមមូលដ្ឋានសហគមន៍ រួមបញ្ចូលទាំងការគាំទ្រ ការអប់រំអំពីការលូតលាស់ ទាំងប្រាជ្ញា ស្មារតី ចិត្តគំនិត និងរាងកាយរបស់កុមារ។ បង្កើនការយល់ដឹងអំពីសារសំខាន់នៃការចូលរួមរបស់កុមារ ដើម្បីពង្រីកទំនាក់ទំនងរវាងកុមារ និងឪពុកម្តាយអ្នកអាណាព្យាបាល អ្នកថែទាំកុមារប្រកបដោយសុវត្ថិភាព និងគ្មានការរើសអើង។

៦.ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ សូមបន្តលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅគ្រប់សកម្មភាពសេដ្ឋកិច្ច និងកសាងបទដ្ឋានគតិយុត្តិ ដើម្បីធានាសុវត្ថិភាពកម្មករនិយោជិតវ័យក្មេង។

៧.កុមារគ្រប់រូបត្រូវចេះជួយអប់រំផ្សព្វផ្សាយអំពីសារសំខាន់នៃការចូលរួមរបស់កុមារ តាមរយៈមិត្តអប់រំមិត្ត ត្រូវជួយផ្សព្វផ្សាយបន្តអំពីសារសំខាន់នៃការចូលរួមរបស់កុមារ នៅតាមគ្រួសារ សាលារៀន និងសហគមន៍ តាមលទ្ធភាពដែលអាចធ្វើបាន។

៨.គ្រប់ស្ថានីយវិទ្យុ និងទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនានា សូមបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការយកចិត្តទុកដាក់លើកស្ទួយវិស័យសុខុមាលភាពកុមារនៅកម្ពុជា ជាពិសេសបង្ការទប់ស្កាត់កុមារកុំឱ្យក្លាយជាជនរងគ្រោះក្នុងគ្រប់រូបភាព។

ជាទីបញ្ចប់ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះសម្តេច ឯកឧត្តម លោកជំទាវ ជនរួមជាតិ ជាពិសេស លោកគ្រូ អ្នកគ្រូ ក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**